ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា

# សាលាបឋមសិក្សា ហ្វ្រានស៊ីស ស្កត់ ឃី (Key)

**Stephanie Stover, នាយិកាសាលា**




# កូនសៀវភៅសម្រាប់ សិស្ស/មាតាបិតា

# ២០១៣-២០១៤

**2230 South 8th Street**
**Philadelphia, PA 19148**



# ការសហការរបស់មាតាបិតា

ខ្ញុំនឹងខំឲ្យអស់ពីសមត្ថភាព ដើម្បីធ្វើយ៉ាងណា៖

* ឲ្យកូនខ្ញុំញ៉ាំអាហារពេលព្រឹកដែលមានជីវជាតិ
* ជូនកូនទៅរៀន ឬយ៉ាងហោចណាស់ឲ្យកូនទៅរៀនឲ្យទាន់ម៉ោង--នៅពេលណាដែលមានសុវត្ថិភាពបំផុត ក្នុងការធ្វើដំណើរ!
* ជួបជាមួយគ្រូរបស់កូនខ្ញុំ ហើយផ្លាស់ប្តូរលេខទូរស័ព្ទគ្នាទៅវិញទៅមក
* បិទទូរទស្សន៍ យ៉ាងហោចណាស់បីម៉ោងក្នុងមួយយប់
* មើល កិច្ចការដែលគ្រូដាក់ឲ្យកូនធ្វើនៅផ្ទះ/របាយការណ៍ពិន្ទុ របស់កូនខ្ញុំ
* អានឲ្យកូនស្តាប់រាល់យប់ ឬឲ្យកូនអានដោយខ្លួនឯង
* និយាយជាមួយ និងស្តាប់ កូនរបស់ខ្ញុំ

| ប្រតិទិនសិក្សាសម្រាប់ឆ្នាំសិក្សា២០១៣-២០១៤ | |
|---|---|
| ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៣ | សម្រាប់តែបុគ្គលិក- *ហ្វឹកហ្វឺនផ្នែកការងារ* |
| ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៣ | សម្រាប់តែបុគ្គលិក- *ហ្វឹកហ្វឺនផ្នែកការងារ* |
| ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០១៣ | ថ្ងៃបុណ្យ Rosh Hashanah- *ការិយាល័យរដ្ឋបាល និងសាលា បិទ* |
| ថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៣ | ថ្ងៃបុណ្យ Rosh Hashanah- *ការិយាល័យរដ្ឋបាល និងសាលា បិទ* |
| ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៣ | ថ្ងៃចូលរៀនដំបូងសម្រាប់ថ្នាក់ទី១-១២ |
| ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៣ | ថ្ងៃចូលរៀនដំបូងសម្រាប់សិស្សមុនថ្នាក់មត្តេយ្យ Head Start & Bright Futures |
| ថ្ងៃទី៩-១៣ ខែកញ្ញា ឆ្នាំ២០១៣ | ជួបសម្ភាសន៍ រវាង គ្រូ និងមាតាបិតា ថ្នាក់មត្តេយ្យ |
| ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៣ | ថ្ងៃចូលរៀនដំបូងសម្រាប់សិស្សថ្នាក់មត្តេយ្យ |

| | |
|---|---|
| ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៣ | ថ្ងៃខួប Columbus- *ការិយាល័យរដ្ឋបាល និងសាលា បិទ* |
| ថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៣ | សម្រាប់តែបុគ្គលិក- *(ថ្ងៃបោះឆ្នោត) ហ្វឹកហ្វឺនផ្នែកការងារ* |
| ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៣ | សម្រាប់តែបុគ្គលិក- *ហ្វឹកហ្វឺនផ្នែកការងារ* |
| ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៣ | ថ្ងៃរំលឹកខួប ទាហានជើងចាស់- *ការិយាល័យរដ្ឋបាល និងសាលា បិទ* |
| ថ្ងៃទី២៨-២៩ ខែវិច្ឆិកា ឆ្នាំ២០១៣ | ថ្ងៃបុណ្យ Thanksgiving- *ការិយាល័យរដ្ឋបាល និងសាលា បិទ* |
| ថ្ងៃទី២៤-៣១ ខែធ្នូរ ឆ្នាំ២០១៣ | វិស្សមកាល រដូវរងារ- *សាលាបិទ* |
| ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ | វិស្សមកាល រដូវរងារ- *ការិយាល័យរដ្ឋបាល និងសាលា បិទ* |
| ថ្ងៃទី១ ខែមករា ឆ្នាំ២០១៤ | ចូលឆ្នាំសកល- *ការិយាល័យរដ្ឋបាល និងសាលា បិទ* |
| ថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤ | ថ្ងៃរំលឹកខួប Dr. Martin Luther King- *ការិយាល័យរដ្ឋបាល និងសាលា បិទ* |
| ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៤ | ថ្ងៃបុគ្គលិកហ្វឹកហ្វឺនផ្នែកការងារ ពេញមួយថ្ងៃ |
| ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៤ | ថ្ងៃប្រធានាធិបតី- *ការិយាល័យរដ្ឋបាល និងសាលា បិទ* |
| ថ្ងៃទី១៤-១៨ ខែមេសា ឆ្នាំ២០១៤ | វិស្សមកាល និទាឃរដូវ- *សាលាបិទ* |
| ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៤ | វិស្សមកាល និទាឃរដូវ– *ការិយាល័យរដ្ឋបាល និងសាលា បិទ* |
| ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១៤ | សម្រាប់តែបុគ្គលិក- *(ថ្ងៃបោះឆ្នោត) ហ្វឹកហ្វឺនផ្នែកការងារ* |
| ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៤ | ថ្ងៃរំលឹកវិញ្ញាណក្ខន្ធ- *ការិយាល័យរដ្ឋបាល និងសាលា បិទ* |
| ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ | ថ្ងៃសិក្សាចុងក្រោយបង្អស់សម្រាប់សិស្សានុសិស្ស |
| ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៤ | សម្រាប់តែបុគ្គលិក- ថ្ងៃចុងក្រោយបង្អស់សម្រាប់បុគ្គលិក- *ដាច់ឆ្នាំសិក្សា* |

ខែកញ្ញា ឆ្នាំ២០១៣

ជូនចំពោះ មាតាបិតា និងអាណាព្យាបាលះ

ខ្ញុំសូមនិយាយមុនគេ «សូមស្វាគមន៍ថ្ងៃបវេសនកាល!» ខ្ញុំសង្ឃឹមថាលោកអ្នកទាំងអស់គ្នា មានសេចក្តីរីករាយចំពោះការឈប់សម្រាកនៅរដូវក្តៅនេះ ហើយរំភើបចិត្តក្នុងការចាប់ផ្តើមឆ្នាំសិក្សាថ្មី ដូចខ្ញុំដែរ។ ខ្ញុំមានកិត្តិយស និងរំភើបចិត្ត ដោយបានធ្វើជានាយិកាសាលាឆ្នាំទីមួយរបស់សាលាបឋមសិក្សា ប្រាន់ស៊ីស ស្កត់ ឃី។ បូករួមទាំងខ្លួនខ្ញុំផ្ទាល់ យើងនឹងមានបុគ្គលិកថ្មីៗជាច្រើនចូលរួមធ្វើការជាមួយក្រុមសាលា ឃី នៅឆ្នាំនេះ ហើយនាងខ្ញុំសង្ឃឹមថាលោកអ្នកនឹងអញ្ជើញមកសាលាដើម្បីជួបជាមួយពួកគាត់។

នាងខ្ញុំឆ្លៀតឱកាសនេះ ដើម្បីផ្តល់ជូនលោកអ្នកនូវព័ត៌មានថ្មីៗអំពី សាលា និងកម្មវិធី របស់យើង។ សាលាចាប់ផ្តើមចូលរៀននៅ ម៉ោង ៨:៣០ ព្រឹក ហើយចេញនៅម៉ោង ៣:០៩ រសៀល ជារៀងរាល់ថ្ងៃ។ ប្រក្រតិទិនដែលមានថ្ងៃខែ ចេញមុនម៉ោង និងបិទសាលា ក៏មាននៅក្នុងសៀវភៅនេះ សម្រាប់ជាដំណឹងជូនដល់លោកអ្នក។

កម្មវិធីបង្ហាត់បង្រៀនរបស់យើងនឹងផ្តោតទៅលើ *ខ្នាតគំរូសំខាន់ៗរបស់រដ្ឋ (Common Core State Standards)* ដែលបានរៀបចំឡើងសម្រាប់សិស្សានុសិស្សថ្នាក់មត្តេយ្យ ដល់ថ្នាក់ទីប្រាំមួយ ទាំងអស់។ យើងនឹងផ្តោតទៅលើវិធានការសិក្សារួមគ្នា និងការបង្កើនភាសាសម្រាប់មុខវិទ្យា នៃកម្មវិធីសិក្សាទាំងអស់។ យើងក៏នឹងបន្តអនុវត្តកម្មវិធី *គន្លឹះទៅកាន់ជោគជ័យ* ដែលមានលក្ខណៈ វិជ្ជមាន លើកទឹកចិត្ត អភិវឌ្ឍ និងផ្តល់រង្វាន់ដល់ ឥរិយាបទ អាកប្បកិរិយា និងអំពើល្អរបស់សិស្ស។

ក្នុងការរៀបចំសម្រាប់ឆ្នាំសិក្សាថ្មី នាងខ្ញុំសូមរំឭកលោកអ្នកអំពីឯកសណ្ឋានដែលយើងចង់បាន។ យោងទៅលើច្បាប់របស់ក្រសួង គេ*តម្រូវ*ឲ្យមានឯកសណ្ឋានសម្រាប់សាលាទៀត នៅឆ្នាំនេះ។ សាលាតម្រូវឲ្យស្លៀក ខោ ឬសំពត់ ពណ៌ទឹកប៊ិចចាស់ និងអាវពណ៌ស។ សាលាមិនអនុញ្ញាតឲ្យពាក់អាវដែលមានមួកគ្របក្បាលនៅសាលាទេ។ សូមកត់សម្គាល់ថា ឯកសណ្ឋាន និងច្បាប់នៃការស្លៀកពាក់ មានពន្យល់ច្បាស់លាស់នៅទំព័រក្រោយនៃសៀវភៅនេះ។

ជាថ្មីម្តងទៀត យើងខ្ញុំទន្ទឹងរង់ចាំឆ្នាំសិក្សាដ៏រំភើបរីករាយជាមួយលោកអ្នក និងកូនរបស់លោកអ្នក នៅសាលាបឋមសិក្សា ឃី ហើយនឹងផ្តោតទៅលើការផ្តល់ឲ្យពួកគេនូវបទពិសោធន៍ដ៏ល្អបំផុតនៅសាលាបឋមសិក្សា។

នាងខ្ញុំសង្ឃឹមថា លោកអ្នកនឹងមកចូលរួម អង្គប្រជុំប្រចាំខែជាមួយមាតាបិតា យប់ជួបប្រជុំជាមួយបុគ្គលិកសាលាដំបូងរបស់យើងខ្ញុំ និងកម្មវិធីសម្រាប់គ្រួសារដែលបានរៀបចំទុកជាមុនផ្សេងៗទៀតទាំងអស់ នៅសាលាឆ្នាំនេះ។ លោកអ្នក អាចរង់ចាំទទួលប្រក្រតិទិនសាលាអំពីកម្មវិធីប្រចាំខែ និងលិខិតជូនដំ ណឹងពិសេសៗ ក្នុងឆ្នាំនេះ ពីនាងខ្ញុំ និងពីគ្រូរបស់កូនលោកអ្នក។

ដោយសេចក្តីស្មោះត្រង់

Stephanie Stover
នាយិកាសាលា

**ជំពូកព័ត៌មានទូទៅ**

ព័ត៌មានខាងក្រោមនេះបានប្រមូលផ្តុំឡើង ដើម្បីផ្តល់ការងាយស្រួល និងអាចមើលបានភ្លាមៗ ដល់លោកអ្នក អំពីច្បាប់ជាមូលដ្ឋាន របស់សាលាបឋមសិក្សា ឃី។ បើលោកអ្នកមានសំណួរអ្វី ឬបើលោកអ្នកចង់បានព័ត៌មានលម្អិតថែមទៀត សូមទាក់ទងមកសាលា។

**លេខទូរស័ព្ទរបស់ការិយាល័យសាលា (២១៥) ៩៥២-៦២១៦**

**លេខទូរសាររបស់ការិយាល័យសាលា (២១៥) ៩៥២-៨៥០៥**

**លេខទូរស័ព្ទរបស់គិលានុបដ្ឋាក (២១៥) ៩៥២-៦៤១៧**

**លេខទូរស័ព្ទរបស់អ្នកផ្តល់ឱ្យវ៉ាទ (២១៥) ៩៥២-៦៤១៦**

**បទល្មើសលើច្បាប់ទី ២៦ (ថ្នាក់មត្តេយ្យ-ទី១២)/ ACT 26 VIOLATIONS (K -12)**

ច្បាប់ទី ២៦ នៃឆ្នាំ១៩៩៥ បានកែប្រែច្បាប់សាលារបស់រដ្ឋផិនស៊ីលវេញ៉ា ច្បាប់រដ្ឋផិនស៊ីលវេញ៉ាតម្រូវឲ្យមានការដេញចេញយ៉ាងហោចណាស់មួយឆ្នាំ ចំពោះសិស្សណាដែលមានអាវុធនៅក្នុងបរិវេណសាលា នៅកន្លែងកម្មវិធីសាលា ឬនៅក្នុងរថយន្តដឹកសិស្សទៅ និងមកពីសាលា។ ច្បាប់បានឲ្យនិយមន័យថា អាវុធជា «កាំបិតគ្រប់ប្រភេទ ឧបករណ៍សម្រាប់កាត់ ដំបងពីរកំណាត់ កាំភ្លើង កាំភ្លើងគ្រាប់ប្រាយ កាំភ្លើងវែង និងសម្ភារៈ ឬឧបករណ៍ ដទៃទៀត ដែលអាចធ្វើឲ្យមានរបួសធ្ងន់ធ្ងរដល់រាងកាយ»។ ច្បាប់មិនតម្រូវថាសិស្ស ប្រើ ឬ ព្យាយាមប្រើ អាវុធនោះទេ។ ជាបន្ថែមទៀត អាវុធសម្រាប់ការពារខ្លួនក៏មិនអាចលើកលែងពីច្បាប់នេះបានដែរ។ មានអាវុធរួមមាន អាវុធដែលគេរកឃើញនៅក្នុងខ្លួន ព្រមទាំង ក្នុងសំពៀត តុ ឬទូដាក់សម្ភារៈនៅសាលា។

ច្បាប់ទី ២៦ តម្រូវឲ្យផ្តល់ដំណឹងទៅប៉ូលីស ហើយសិស្សមានសិទ្ធិឡើងសវនាការជាផ្លូវការ។ សិស្សានុសិស្សដែលទទួលការអប់រំពិសេសក៏ប៉ះទង្គិចដោយច្បាប់ទី២៦នេះដែរ។ ទោះជាច្បាប់រដ្ឋសហព័ន្ធតម្រូវឲ្យប្រើនិតិវិធីពិសេស មុនពេលដាក់ទណ្ឌកម្មសិស្សដែលទទួលការអប់រំពិសេស ក៏ការអនុវត្តច្បាប់ទី ២៦ មិនអាចដាក់ទណ្ឌកម្មពួកគេចំពោះអំពើដែលទាក់ទងទៅនឹងពិការភាពរបស់ពួកគេបានដែរ។ ទោះជាយ៉ាងដូច្នេះក្តី សិស្សទទួលការអប់រំពិសេសដែលយកអាវុធមកសាលា អាចផ្លាស់ទៅកម្មវិធីដែលអប់រំតាមវិធីផ្សេងទៀត សម្រាប់រយៈពេល៤៥ថ្ងៃ ក្នុងពេលដែលធ្វើសវនាការតាមច្បាប់នៃការគោរពសិទ្ធិរបស់បុគ្គល។

នៅពេលដែលសិស្សមានអាយុក្រោម១៧ឆ្នាំត្រូវគេដេញចេញពីសាលា ហើយមិនអាចរកសាលាផ្សេងទៀតទៅរៀនបានក្នុងកំឡុងពេល៣០ថ្ងៃ ចាប់ពីថ្ងៃដែលគេដេញចេញ ក្រុមគ្រួសាររបស់សិស្សត្រូវជម្រាបទៅក្រសួងតាមការសរសេរជាលាយលក្ខណ៍អក្សរ អំពីកម្មវិធីដែលសិស្សត្រូវការ។ បន្ទាប់មក វាជាភារៈកិច្ចរបស់ក្រសួងអប់រំក្នុងការផ្តល់កម្មវិធីអប់រំនេះ ដល់សិស្ស។ សិស្សដែលទទួលការអប់រំពិសេសមានសិទ្ធិទទួលការអប់រំពិសេសជាបន្ត រហូតដល់ពេលបញ្ចប់ការសិក្សា ឬដល់អាយុ២១ឆ្នាំ ទោះជាត្រូវគេបណ្តេញចេញក៏ដោយ។

តាមច្បាប់ទី ២៦ បើសិនជាសិស្សចុះឈ្មោះរៀននៅក្រសួងអប់រំផ្សេងទៀត «មាតាបិតា អាណាព្យាបាល ឬអ្នកដទៃទៀតដែលទទួលខុសត្រូវលើសិស្ស» ដែលត្រូវគេបណ្តេញចេញ ត្រូវផ្តល់ពាក្យសម្បថឲ្យទៅក្រសួងអប់រំថ្មី ថាតើសិស្សធ្លាប់បានគេ បញ្ឈប់បណ្តោះអាសន្ន ឬដេញចេញពីសាលារដ្ឋ ឬសាលាឯកជន នៅរដ្ឋណាមួយ ដោយសារបទល្មើសដែលទាក់ទងនឹង អាវុធ គ្រឿងញៀន សុរា មានបំណងធ្វើឲ្យអ្នកណាម្នាក់មានរបួស ឬបានធ្វើនូវអំពើហឹង្សានៅក្នុងបរិវេណសាលា។ សេចក្តីរាយការណ៍នេះ នឹងក្លាយទៅជាផ្នែកនៃសំណុំឯកសាររបស់សិស្ស។ នៅពេលដែលសេចក្តីរាយការណ៍នេះបានប្រគល់ឲ្យរួចហើយ គេត្រូវទទួលសិស្ស ហើយផ្តល់ការអប់រំដូចគ្នានឹងសិស្សដ៏ទៃទៀតនៅក្នុងក្រសួងនោះដែរ។ ជនណាម្នាក់ដែលផ្តល់ព័ត៌មានខុសដោយចេតនា គេអាចកាត់ទោសបទល្មើសមជ្ឈិមកម្រិតទីបី ដែលអាចដាក់ទណ្ឌកម្មតាមការពិន័យជាប្រាក់ ចំនួន ២.៥០០$ ឬជាប់គុកមួយឆ្នាំ។ ការលើកលែងតែមួយចំពោះតម្រូវការនេះ គឺថាសិស្សដែលត្រូវគេដេញចេញពីក្រសួងណាមួយចំពោះបទល្មើសលើច្បាប់ទី២៦ អំពីការមានអាវុធ អាចឲ្យគេបដិសេធសិស្សពីក្រសួងថ្មីសម្រាប់រយៈពេលនៃការដេញសិស្សចេញនៅក្រសួងចាស់។ អគ្គនាយកនៃក្រសួងអប់រំនីមួយៗ មានអំណាចសុំឲ្យដាក់ទណ្ឌកម្ម ជាជាងការដេញចេញ ដោយយោងទៅលើបុគ្គលម្នាក់ៗ។ បើសិនជាក្រសួងអប់រំបដិសេធ មិនពិចារណាពីកាលៈទេសៈរបស់សិស្សម្នាក់ៗ មាតាបិតាអាចមានហេតុផលដើម្បីស្នើសុំតវ៉ាពីការដេញចេញនៅតុលាការ។

**ច្បាប់ប្រឆាំងនឹងការគូសវាសលេងខុសច្បាប់**

គេ**មិន**អនុញ្ញាតឲ្យសិស្សានុសិស្សយក ប៊ិចធំៗសម្រាប់គូរ ឬផាត់ពណ៌ (markers) និង/ឬ ប៊ិច ដែលមិនអាចលប់បានមកសាលាទេ។ គេនឹងដកហូតរបស់ទាំងនេះដោយមិនអោយវិញ។ **សិស្សានុសិស្សដែលសរសេរនៅលើ និង/ឬ ធ្វើឲ្យខូចទ្រព្យសម្បត្តិរបស់ក្រសួងអប់រំ គឺអាចឲ្យគេ ចាប់ខ្លួន និង ដាក់វិន័យផ្សេងៗ។**

**ការមកដល់ និងការចេញពី សាលា**

សាលានឹងចាប់ផ្តើមដំណើរការនៅម៉ោង ៨:៣០ ព្រឹក។ សិស្សានុសិស្សទាំងអស់ត្រូវតម្រង់ជួរនៅក្នុងទីធ្លាសាលានៅម៉ោង ៨:៣០ ព្រឹក ជាមួយសិស្សរួមថ្នាក់របស់ពួកគេ បើសិនជាអាកាសធាតុល្អ។ នៅពេលណាតម្រង់ជួររួចហើយ សិស្សានុសិស្សនឹងចូលក្នុងអាគារជាមួយសិស្សរួមថ្នាក់របស់ពួកគេតាមទ្វារទាំងបួនដែលប្រើសម្រាប់គៀសអគ្គីភ័យ។ ***នៅពេលដែលអាកាសធាតុមិនល្អ*** សិស្សានុសិស្សត្រូវចូលក្នុងអាគារ តាមទ្វារធំ នៅផ្លូវ លេខ៨ និង ផ្លូវ Wolf ដែលមានអ្នកចាំប្រាប់កន្លែងដែលពួកគេត្រូវតម្រង់ជួរ។ សូមកត់សម្គាល់ថា ក្រោយម៉ោង ៨:២០ ព្រឹក សិស្សានុសិស្ស ថ្នាក់មត្តេយ្យ និងថ្នាក់ទីមួយ ទាំងអស់នឹងតម្រង់ជួរនៅជាន់ទីមួយ នៅក្រៅថ្នាក់រៀនរបស់ពួកគេ។ សិស្សានុសិស្សទាំងអស់ដែលមកដល់សាលាមុនម៉ោង ៨:២០ ព្រឹក គប្បីទៅកាន់ ជាន់ក្រោមដី ដើម្បីឲ្យមានអ្នកជួយមើល នៅពេលណាដែលមានអា

កាសធាតុមិនល្អ។

ឆ្នាំនេះ សិស្សនឹងចេញពីរៀននៅម៉ោង ៣:០៩ រសៀល។ សិស្សានុសិស្សថ្នាក់ទី បួន ទីប្រាំ និង ទីប្រាំមួយ នឹងមានអ្នកជូនទៅកាន់ទ្វារចេញនៅផ្លូវលេខ៨ ហើយឲ្យចេញទៅផ្ទះ។ គេនឹងនាំសិស្សានុសិស្សថ្នាក់ទីពីរ និងទីបី ទៅកាន់ទ្វារចេញនៅផ្លូវ Mildred ហើយឲ្យចេញទៅផ្ទះ។ សិស្សានុសិស្សថ្នាក់មត្តេយ្យ និងថ្នាក់ទីមួយ ទាំងអស់ នឹងចេញតាមទីធ្លាសាលា នៅក្រោយអាគារ។

ក្នុងពេលដែលមានធ្លាក់ទឹកកកច្រើន គេនឹងឲ្យសិស្សានុសិស្សទាំងអស់ចេញតាមទ្វារនៅផ្លូវលេខ៨។ ត្រូវមានការរៀបចំជាមុន សម្រាប់សិស្សានុសិស្សដែលចេញតម្រង់ឆ្ពោះទៅផ្ទះ ឬមានអ្នកមកទទួលភ្លាមៗ។ ដោយសារកន្លែងតូច និងគ្មានបុគ្គលិកជួយមើល យើងខ្ញុំគ្មានសមត្ថភាពដើម្បីផ្តល់ការមើលថែ ឬការជួយមើល ក្រោយម៉ោងសិក្សាបានទេ។

**វត្តមានអវត្តមាន**

ក្មេងដែលមិនមកសាលានឹងមានការលំបាកក្នុងការសិក្សាអ្វីៗដែលសំខាន់ ដើម្បីទទួលជោគជ័យក្នុងការសិក្សា។ ហេតុដូច្នេះហើយ វាជាការចាំបាច់ដែលកូនលោកអ្នកត្រូវមករៀនឲ្យបានទៀងទាត់។ ពេលវេលាដែលបាត់បង់ទៅហើយ គឺពិបាកនឹងបង្គ្រប់វិញណាស់ ហើយគ្រប់នាទី ជារៀងរាល់ថ្ងៃ សុទ្ធតែសំខាន់ទាំងអស់។ មិនត្រូវទុកសិស្សឲ្យនៅផ្ទះទេ លើកលែងតែនៅពេលពួកគេឈឺ។ តាមច្បាប់ លោកអ្នកជាអ្នកទទួលខុសត្រូវក្នុងការធ្វើលិខិតពន្យល់ ឬលិខិតពីវេជ្ជបណ្ឌិត ទៅឲ្យគ្រូរបស់កូន **ក្នុងកំឡុងពេល៣ថ្ងៃ ចាប់ពីថ្ងៃដែលកូនមិនមករៀន** បញ្ជាក់ពីមូលហេតុនៃអវត្តមាន។ វាជាច្បាប់របស់ក្រសួងអប់រំ ចំពោះក្មេងណាដែលមិនបានផ្តល់លិខិតពន្យល់ពីអវត្តមានរបស់ពួកគេក្នុងកំឡុងពេល៣ថ្ងៃ ចាប់ពីថ្ងៃអវត្តមាន នឹងទទួលការកំណត់នៃអវត្តមានជាផ្លូវការថាជា «អវត្តមានខុសច្បាប់»។

**កម្មវិធី អាហារពេលព្រឹក/អាហារថ្ងៃត្រង់**

សិស្សានុសិស្សទាំងអស់របស់យើងមានសិទ្ធិញុំា អាហារថ្ងៃត្រង់ និងអាហារពេលព្រឹក ដោយឥតគិតថ្លៃ។ គ្មានលិខិតសម្រាប់បំពេញទេ។ គេនឹងផ្តល់អាហារពេលព្រឹកទៅក្មេងទាំងអស់ដែលចង់ញុំា នៅពេលដែលពួកគេចូលក្នុងបន្ទប់ត្រៀមខ្លួនចូលថ្នាក់នៅម៉ោង ៨:៣០ ព្រឹក។ ដូច្នេះហើយ វាជាការសំខាន់ណាស់ដែលកូនលោកអ្នកមកសាលាឲ្យទាន់ពេលរៀងរាល់ថ្ងៃ។ យើងមិនចង់ឲ្យខាតពេលដ៏សំខាន់សម្រាប់រៀននៅក្នុងថ្នាក់ ដោយសារការញុំាអាហារនោះទេ។

សិស្សានុសិស្សទាំងអស់ត្រូវញុំាអាហារថ្ងៃត្រង់នៅក្នុងសាលា ហើយយើងខ្ញុំសំណូមពរឲ្យពួកគេញុំាអាហារថ្ងៃត្រង់ដែលសាលាផ្តល់ឲ្យ។ មានការលើកលែងចំពោះមូលហេតុមានជម្ងឺ និងសាសនា ផ្សេងៗ។ សិស្សានុសិស្សដែលយកអាហារថ្ងៃត្រង់មកខ្លួនឯង គប្បីយកមកជារៀងរាល់ថ្ងៃ។ មូលហេតុព្រោះថា រដ្ឋាភិបាលនឹងធ្វើការត្រួតពិនិត្យយ៉ាងតឹងរឹង ហើយយើងត្រូវដឹងថា តើត្រូវទិញអាហារថ្ងៃត្រង់ចំនួនប៉ុន្មានក្នុងមួយថ្ងៃៗ។ គេមិនអនុញ្ញាតឲ្យញុំា អាហារឥតជីវជាតិ ភេសជ្ជៈដប ឬទឹកក្រូចនៅក្នុងសាលាទេ។ គេមិនអនុញ្ញាតឲ្យក្មេងញុំាស្ករគ្រាប់ ឬទំពារស្ករកៅស៊ូ នៅក្នុងសាលាទេ។

បើសិនជាលោកអ្នកមានសំណួរអ្វីអំពីកម្មវិធី អាហារពេលព្រឹក និង/ឬ អាហារថ្ងៃត្រង់ របស់សាលា សូមទាក់ទងមកសាលា ដើម្បីជ្រាបព័ត៌មានបន្ថែម។

**អាកប្បកិរិយាដែលសម្លុតធ្វើបាបគេ**

ហាមឃាត់ដាច់ខាតនូវការសម្លុតធ្វើបាបគេ។ ការសម្លុតធ្វើបាបគេកើតមានឡើងនៅពេលសិស្សណាម្នាក់មានអាកប្បកិរិយាដែល រារាំង ឬបំបាក់ទឹកចិត្ត សិស្សដទៃទៀតមិនឲ្យប្រើសិទ្ធិរបស់គេសម្រាប់ការអប់រំ។ អាកប្បកិរិយាដែលសម្លុតធ្វើបាបគេ បានឲ្យនិយមន័យថា ជាអាកម្បកិរិយាដែល បំពាន ឬផ្តល់ការឈឺចាប់ ម្តងហើយម្តងទៀត ក្នុងរយៈកាលមួយ តាមរយៈទំនាក់ទំនងនៃអំណាចដែលមានមិនស្មើគ្នា (ដែលទាក់ទងនឹង ភេទ កម្លាំងកាយ ឬកម្លាំងចិត្ត ការទទួលស្គាល់នៅក្នុងសង្គម ។ល។)។ អាកប្បកិរិយាបែបនេះ រួមមាន ការនិយាយលូកលាន់ ការនិយាយចំអក ការគម្រាមកំហែង ការបង្ខិតបង្ខំ ការយាយីម្តងហើយម្តងទៀត ការធ្វើបាប ការសង្កត់សង្កិន ការគម្រាមដល់សិស្សានុសិស្ស បុគ្គលិកសាលា ឬអ្នកមកកាន់សាលា ឬការបដិសេធអ្នកណាម្នាក់ ដោយរាងកាយ ដោយផ្លូវចិត្ត ឬ ភេទ។ គេអាចដាក់ទណ្ឌកម្មសិស្សដែលមានកំហុស ចំពោះការសម្លុតធ្វើបាបគេ រហូតដល់រយៈពេលដប់ថ្ងៃ បញ្ជូនទៅមណ្ឌលអប់រំតាមវិធីអប់រំផ្សេងទៀត និង/ឬ ដេញចេញពីក្រសួងអប់រំ។

**សេវាផ្តល់ឱវាទ**

អ្នកផ្តល់ឱវាទរបស់យើងខ្ញុំមានការត្រៀមខ្លួនជាស្រេចដើម្បីជួយក្មេង និងក្រុមគ្រួសារ។ គាត់ផ្តល់ជំនួយដល់ក្មេងៗ និងមាតាបិតា ដែលមានអ្នកខ្លះត្រូវ គ្រូ និងការិយាល័យសាលា ជាអ្នកបញ្ជូនមក។ គាត់នឹងសហការយ៉ាងជិតស្និតជាមួយ មាតាបិតា និងអង្គការនៅក្នុងសហគមន៍។ បើសិនជាលោកអ្នក ឬកូនរបស់លោកអ្នកមានបញ្ហា អ្នកផ្តល់ឱវាទ គឺជាអ្នកដែលលោកអ្នកត្រូវជួបជាមួយ។ សូមមកកាន់ការិយាល័យសាលា ឬទូរស័ព្ទមកគាត់ដោយផ្ទាល់ បើសិនជាលោកអ្នកចង់និយាយជាមួយគាត់។ បញ្ហាធ្ងន់ធ្ងរជាច្រើនអាចដោះស្រាយបាន ដោយការសហការគ្នារវាង មាតាបិតា អ្នកផ្តល់ឱវាទ និងគ្រូ។ សាលា ឃី ក៏មានមោទនភាពដើម្បីផ្តល់សេវាផ្តល់ឱវាទ ដូចបានរៀបរាប់ខាងលើនេះ (តាមភាសាកំណើត) ដល់សិស្សានុសិស្សរបស់យើងដែលមានក្រុមគ្រួសារនិយាយភាសា ខ្មែរ លាវ ណេប៉ាល់ ខារិន ភូមា វៀតណាម ចិន (Cantonese) និងអេស្ប៉ាញ៉ុល។

**ការសម្លុតធ្វើបាបតាមអ៊ិនធ័រណិត**

ការសម្លុតធ្វើបាបតាមអ៊ិនធ័រណិត ក៏គេមានការហាមឃាត់យ៉ាងតឹងរឹងដែរ ហើយមានន័យថា ជាការសម្លុតធ្វើបាបតាមរយៈការប្រើគ្រឿងអេឡិចត្រូនិច ដូចជា អ៊ីមែល ការសរសេរឆ្លងឆ្លើយភ្លាមៗតាមកុំព្យូទ័រ ការសរសេរឆ្លងឆ្លើយតាមទូរស័ព្ទដៃ សរសេរដាក់ក្នុងអ៊ិនធ័រណិត ចែកគេឯងមើល រូបថត និងវីដេអូ សរសេរឆ្លងឆ្លើយគ្នាតាម

បន្ទប់សន្ទនាតាមអិនធ័រណិត ទូរស័ព្ទដៃ គេជ័រ (pagers) ហើយសិស្សានុសិស្សដែលមានកំហុស ចំពោះការសម្លុតធ្វើបាបតាមអិនធ័រណិត អាចឲ្យគេដាក់ទណ្ឌកម្ម រហូតដល់រយៈពេលដប់ថ្ងៃ បញ្ជូនទៅមណ្ឌលអប់រំតាមវិធីផ្សេងទៀត និង/ឬ ដេញចេញពីក្រសួងអប់រំ។

### វិធីដាក់ទណ្ឌកម្ម/ក្រមសីលធម៌នៃអាកប្បកិរិយាសិស្ស

នៅពេលណាមានបទល្មើសស្រាលៗលើវិន័យសាលា ភាគច្រើនត្រូវបានដោះស្រាយដោយគ្រូបង្រៀន ឬបុគ្គលិកដែលទទួលខុសត្រូវ។ ការស្ដីបន្ទោស ឬការដកសិទ្ធិ ត្រូវយកមកដោះស្រាយចំពោះបញ្ហាភាគច្រើន។ ក្នុងករណីខ្លះ ត្រូវដាក់ទណ្ឌកម្មក្រោយម៉ោងសិក្សា។ គេនឹងជម្រាបមាតាបិតាអំពីមូលហេតុ ថ្ងៃខែ និងរយៈពេល នៃការដាក់ទណ្ឌកម្ម។

គេនឹងចែកចាយក្រមសីលធម៌នៃអាកប្បកិរិយាសិស្ស ដែលជាឯកសារចងក្រងឡើងដោយក្រសួង ជូនដល់មាតាបិតាទាំងអស់។ ឯកសារនេះពន្យល់ពីច្បាប់ផ្សេងៗ ដែលគ្រប់គ្រងលើការប្រព្រឹត្តផ្សេងៗនៅក្នុងក្រសួង។ វាពាក់ព័ន្ធនឹងការប្រព្រឹត្តដែលកើតមានឡើងនៅ៖ លើទីធ្លាសាលាគ្រប់ពេលវេលា ក្រៅទីធ្លាសាលានៅពេលដែលមានសកម្មភាពសាលា ក្នុងពិធី ឬកម្មវិធី នៅពេលធ្វើដំណើរ ទៅ និងមកពី សាលា ។ល។ សិទ្ធិ និងការទទួលខុសត្រូវ បទល្មើស ផលវិបាក និងវិធីដាក់ទណ្ឌកម្ម មានពន្យល់នៅក្នុងឯកសារនេះ។

យើងខ្ញុំដឹងថា មាតាបិតាចង់ឲ្យគេផ្ដល់ដំណឹងអំពីអាកប្បកិរិយារបស់កូន។ យើងខ្ញុំក៏ដឹងដែរថា តាមការសហការគ្នា យើងអាចសម្រេចបាននូវអ្វីៗដែលអាចធ្វើឲ្យសិស្សល្អ។ ដោយហេតុនេះ យើងខ្ញុំសូមសច្ចា ហើយខំប្រឹងឲ្យអស់ពីសមត្ថភាព ដើម្បីជូនដំណឹងដល់លោកអ្នក។

### គ្រឿងអេឡិចត្រូនិច និងប្រដាប់លេង

ការប្រើ ទូរស័ព្ទដៃ game boys អាយផត់ (ipods) និង គ្រឿងអេឡិចត្រូនិច ផ្សេងៗទៀតទាំងអស់ ព្រមទាំង ប្រដាប់ក្មេងលេង អាចធ្វើឲ្យរំខានដល់បរិយាកាសអប់រំ។ ការប្រើទូរស័ព្ទដៃនៅម៉ោងរៀនក៏អាចកាត់បន្ថយសុវត្ថិភាពដល់អ្នករាល់គ្នានៅក្នុងអាគារសាលាដែរ។ ចំពោះគណកម្មាធិការកែទម្រង់សាលារៀន ទូរស័ព្ទដៃ ប៊ីព័រ (beepers) ប៊ិចកាំរស្មី (laser pens) game boys អាយផត់ (ipods) ។ល។ ត្រូវគេ***ហាមឃាត់***មិនឲ្យមាននៅក្នុងសាលា។ បើសិស្សយករបស់ទាំងនេះចូលក្នុងអាគារ គេនឹងដកហូតរបស់ទាំងនេះ។ ឧបត្តិហេតុលើកទីមួយ នឹងបណ្ដាលឲ្យមានការជួបប្រជុំជាមួយមាតាបិតា ដែលគេអាចប្រគល់របស់នោះវិញ (**មានតែ** មាតាបិតា/អាណាព្យាបាល ទេដែលអាចទទួលរបស់នេះវិញបាន)។ បទល្មើសលើកទីពីរ នឹងបណ្ដាលឲ្យគេទុករបស់នេះរហូតដល់ថ្ងៃចប់សាលា។ *សាលាបឋមសិក្សា឴ ឃី នឹងមិនទទួលខុសត្រូវចំពោះ ទូរស័ព្ទដៃ ឬគ្រឿងអេឡិចត្រូនិចផ្សេងៗទៀត ដែលបាត់ ត្រូវគេលួច ឬបែកបាក់ ទេ ព្រោះវាជាច្បាប់របស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យាថា សិស្សានុសិស្សមិនត្រូវយក ទូរស័ព្ទដៃ ឬ គ្រឿងអេឡិចត្រូនិចផ្សេងៗទៀត មកសាលាបានទេ។*

### ការបិទសាលានៅពេលមានអាសន្ន - ព្យុះទឹកកក

១. ស្ដាប់វិទ្យុ ឬមើលទូរទស្សន៍ ដែលចាប់ផ្ដើមផ្សាយនៅម៉ោង ៥:០០ ព្រឹក។ គេនឹងប្រកាសថាតើសាលារដ្ឋនៅទីក្រុងហ្វីឡាដែលហ្វ្យា បិទ ឬអត់។
២. ***សូមកុំទូរស័ព្ទមកការិយាល័យសាលា។ ខ្សែទូរស័ព្ទនៅការិយាល័យសាលាត្រូវទុកឲ្យទំនេរសម្រាប់ភាពអាសន្ន។ សូមស្ដាប់ប៉ុស្ដិ៍វិទ្យុ KYW ដើម្បីជ្រាបព័ត៌មានដែលទាក់ទងដល់ការបិទសាលា។ វិទ្យុ KYW លេខ 1060 on the AM frequency ។***
៣. ធ្វើយ៉ាងណាឲ្យយើងខ្ញុំមាននៅក្នុងសំណុំឯកសារនូវ អាស័យដ្ឋាន និងលេខទូរស័ព្ទ របស់សាច់ញាតិ ឬអ្នកជិតខាង ដែលគេអាចបញ្ជូនកូនលោកអ្នកទៅគាត់ នៅពេលសាលាបិទមុនម៉ោង។ គឺជាការសំខាន់ណាស់ដែលយើងខ្ញុំត្រូវមាន **លិខិតសម្រាប់ទាក់ទងនៅពេលមានអាសន្ន** សម្រាប់ក្មេងគ្រប់រូបនៅសាលារបស់យើង។

### អង់គ្លេសសម្រាប់អ្នកដែលនិយាយភាសាដទៃទៀត (ESOL)

កម្មវិធី អង់គ្លេសសម្រាប់អ្នកដែលនិយាយភាសាដទៃទៀត ផ្ដល់ការបង្ហាត់បង្រៀនភាសាអង់គ្លេសយ៉ាងហ្មត់ចត់ ជារៀងរាល់ថ្ងៃដល់សិស្សានុសិស្សទាំងអស់ដែលនិយាយភាសាផ្សេងទៀត។ គេបង្រៀនក្មេងតាមរបៀបផ្សេងៗ ដើម្បីអភិវឌ្ឍចំណេះដឹងក្នុងការប្រាស្រ័យទាក់ទង ធ្វើឲ្យមានការយល់ដឹងពីវប្បធម៌ និងបង្កើន ជំនឿទុកចិត្ត និងមោទនភាព របស់សិស្សានុសិស្ស។ កម្មវិធីរបស់យើងក៏ផ្ដល់ការជួយបង្រៀនបន្ថែមសម្រាប់សិស្សានុសិស្សដែលត្រូវការជំនួយបន្ថែមក្នុងការសិក្សា។

### កម្មវិធីគណិតវិទ្យាប្រចាំថ្ងៃ - ថ្នាក់មត្តេយ្យ ដល់ថ្នាក់ទី៥ បរិបទគណិតវិទ្យា - ថ្នាក់ទី៦

ក្រសួងអប់រំតម្រូវឲ្យសាលាបឋមសិក្សានីមួយៗផ្ដល់ការបង្ហាត់បង្រៀនគណិតវិទ្យាចំនួន៩០នាទី ក្នុងមួយថ្ងៃ ប្រើកម្មវិធី Everyday Math (គណិតវិទ្យាប្រចាំថ្ងៃ)។ កម្មវិធីគណិតវិទ្យានេះបានរៀបចំឡើងដើម្បីបណ្ដុះការយល់ដឹងតាមគំនិត និងការស្ទាត់ជំនាញនៃវិធីដោះស្រាយគណិតវិទ្យា។ កម្មវិធីគណិតវិទ្យាប្រចាំថ្ងៃ ធ្វើតាមខ្នាតគំរូគណិតវិទ្យារបស់រដ្ឋ និងទូទាំងប្រទេស ហើយបានរៀបចំឡើងដើម្បីផ្ដល់ឲ្យសិស្សានុសិស្ស នូវបទពិសោធន៍ខាងគណិតវិទ្យា ដែលអាចជួយពួកគេធ្វើកិច្ចការឲ្យបានល្អនៅពេលប្រឡង PSSA។ សិស្សានុសិស្សថ្នាក់ទីប្រាំមួយរបស់យើងនឹងរៀនជាមួយកម្មវិធី Math in Context Program (បរិបទគណិតវិទ្យា) ដើម្បីត្រៀមពួកគេសម្រាប់ថ្នាក់ទី៧ និង ទី៨។

**FamilyNet (បណ្តាញគ្រួសារ)**

ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា បានបង្កើត "FamilyNet" ដែលអនុញ្ញាតឲ្យក្រុមគ្រួសារមើលទិន្នន័យ នៃការរីកចម្រើន ពិន្ទុក្នុងរបាយការណ៍ពិន្ទុ វត្តមានអវត្តមាន ពិន្ទុនៃការប្រឡងទូទៅ និងជំនួយក្នុងការបង្ហាត់បង្រៀន របស់កូន។ លោកអ្នកត្រូវការអ៊ិនធ័រណិត ហើយធ្វើតាមលំដាប់ខាងក្រោមនេះ៖

**ទី១៖ យកឈ្មោះប្រើ និង ពាក្យសម្ងាត់បណ្តោះអាសន្ន/Get your username and temporary password។**

**ចូលទៅ** http://www.phia.k12.pa.us/parents/familynet ហើយចុចលើពាក្យ"Register Now"។ **កំណត់សម្គាល់៖** លោកអ្នកនឹងត្រូវការ ឈ្មោះ ថ្ងៃកំណើត និងអត្តលេខ របស់កូន (អត្តលេខរបស់សិស្សអាចឃើញនៅលើរបាយការណ៍ពិន្ទុរបស់កូនលោកអ្នក)។

**ទី២៖ ចុចចូលទៅ SchoolNet (បណ្តាញសាលា)/Log into SchoolNet។**

**ចូលទៅ** http://phila.schoolnet.com ហើយចុចលើរូបសញ្ញាពណ៌ខៀវដែលមានពាក្យថា "Parents/Guardians" ហើយបន្ទាប់មកចុចលើរូបសញ្ញាពណ៌លឿងដែលមានពាក្យថា "Log onto FamilyNet"។ លោកអ្នកក៏ត្រូវគេសុំឲ្យបង្កើត ពាក្យសម្ងាត់ពិតប្រាកដរបស់លោកអ្នក។

**កំណត់សម្គាល់៖** ក្រោយពីបានបង្កើត ពាក្យសម្ងាត់ពិតប្រាកដរបស់លោកអ្នករួច លោកអ្នកអាចបំភ្លេចពាក្យសម្ងាត់ពីមុនរបស់លោកអ្នក។

**ទី៣៖ រកមើលព័ត៌មានរបស់កូនលោកអ្នក/Finding your child's information។**

ចុចលើ "student profile" របស់កូន នៅកណ្តាលទំព័រ។ នៅពេលចូលក្នុងជីវប្រវត្តិ/profile របស់កូនហើយ លោកអ្នកអាចមើលការចុះឈ្មោះ ឯកសារអំពីការសិក្សា ពិន្ទុនៃការប្រឡងទូទៅ កម្មវិធី និងការប្រឡង Benchmark របស់កូន។

**កំណត់សម្គាល់៖** ចុចលើពាក្យ HOME នៅលើបន្ទាត់ពណ៌លឿង ខាងលើទំព័រ ដើម្បីរកមើលសកម្មភាពផ្សេងៗសម្រាប់កូន។

***បើសិនលោកអ្នកមានសំណួរអ្វីដែលទាក់ទងនឹង FamilyNet សូមអ៊ីមែលទៅ*** familynet@philasd.org

**ការណែនាំសម្រាប់ការពន្យាម៉ោងបើកសាលាដោយសារអាកាសធាតុមិនល្អ**

នៅពេលមានអាកាសធាតុមិនល្អ ក្រសួងអាចសម្រេចចិត្តពន្យាម៉ោងបើកសាលា។ ការសម្រេចចិត្តពន្យាម៉ោងបើកសាលានឹងយោងទៅលើយោបល់ពីការិយាល័យរបស់ចៅហ្វាយក្រុង និងអង្គការជំនួយផ្សេងៗទៀតរបស់សាលាក្រុង។ នៅពេលណាមានការសម្រេចចិត្តពន្យាម៉ោងបើកសាលារួចហើយ គេនឹងប្រកាសតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងតំបន់ និងតាមរយៈការធ្វើទំនាក់ទំនងរបស់ក្រសួងអប់រំ។ នៅពេលណាមានការពន្យាម៉ោងបើកសាលា សាលា និងកម្មវិធីមុនថ្នាក់មត្តេយ្យ ទាំងអស់ នឹងបើកនៅម៉ោង ១០:០០ ព្រឹក។ ម៉ោងចេញពីរៀននឹងនៅដដែល (៣:០៩ រសៀល)។

**ជំនួយផ្នែកសុខភាព/HEALTH SERVICES**

គិលានុបដ្ឋាយិកាសាលារបស់យើងខ្ញុំ ជាអ្នកទទួលខុសត្រូវចំពោះការ ពិនិត្យភ្នែក វាស់កំពស់ ថ្លឹងទម្ងន់ សិស្សានុសិស្សទាំងអស់ ប្រចាំឆ្នាំ។ ការពិនិត្យសោតប្បសាទ ធ្វើឡើងចំពោះក្មេងថ្នាក់មត្តេយ្យ ដល់ថ្នាក់ទីបី និងក្មេងណាដែលមានបញ្ហាជាមួយសោតវិញ្ញាណ។ គេតម្រូវឲ្យ មានការពិនិត្យ សរីរាងកាយ និងធ្មេញ នៅពេលចូលរៀននៅក្រសួងអប់រំ និងសម្រាប់សិស្សានុសិស្សថ្នាក់ទី៦។ គេក៏តម្រូវឲ្យមានការពិនិត្យមើលជម្ងឺវៀចឆ្អឹងខ្នងសម្រាប់សិស្សានុសិស្សថ្នាក់ទី៦ដែរ។ គិលានុបដ្ឋាយិកាសាលារបស់យើងខ្ញុំនឹងធ្វើការពិនិត្យទាំងនេះ។

ជាបន្ថែមទៀត គិលានុបដ្ឋាយិកានឹងជួយដល់ការធ្វើការណាត់ជួបជាមួយ មន្ទីរព្យាបាល ពេទ្យធ្មេញ ការធានារ៉ាប់រងសុខភាព និងវ៉ែនតា សម្រាប់អ្នកដែលស្នើសុំជំនួយទាំងនេះ។ ការអនុលោមតាមច្បាប់របស់ក្រសួង គេ**តម្រូវ**ឲ្យលោកអ្នកជួបជាមួយគិលានុបដ្ឋាយិកា បើសិនជាកូនត្រូវការ ញ៉ាំថ្នាំដែលមានវេជ្ជបញ្ជា ឬបើសិនជាកូនមានបញ្ហាសុខភាព។

គេ**តម្រូវ**ឲ្យមានការចាក់ថ្នាំបង្ការរោគ ហើយត្រូវចាក់ឲ្យបានគ្រប់ចំនួន។ តារាងសម្រាប់ការតម្រូវឲ្យមានការចាក់ថ្នាំបង្ការរោគ ជាមួយនឹងពេលដែលត្រូវចាក់ អាចយកពីគិលានុបដ្ឋាយិកាបាន។

នៅក្នុងថ្ងៃសិក្សា គិលានុបដ្ឋាយិកាក៏ពិនិត្យមើលក្មេងណាដែលមិនស្រួលខ្លួន ឬផ្តល់ការព្យាបាលបឋមនៅពេលណាចាំបាច់។ នៅពេលណាចាំបាច់ គេនឹងទាក់ទងទៅមាតាបិតាឲ្យមកយកកូនទៅផ្ទះ និង/ឬ ប្រាប់ឲ្យទៅរកជំនួយព្យាបាលបន្ថែម។ ដោយសារគិលានុបដ្ឋាយិការធ្វើការតែ២ថ្ងៃ ក្នុងមួយសប្តាហ៍ យើងខ្ញុំសុំឲ្យលោកអ្នកទុកកូនដែលឈឺឲ្យនៅផ្ទះ។ បើសិនជាក្មេងឈឺនៅថ្ងៃរៀន ត្រូវធ្វើតាមខដែលមានចែងដើម្បីឲ្យក្មេងចេញពីសាលាតាមច្បាប់ ដោយសុំឲ្យមនុស្សពេញវ័យដែលជាអ្នកទទួលខុសត្រូវ មកកាន់ការិយាល័យសាលាដើម្បីទទួលកូន និងចុះហត្ថលេខា សម្រាប់ការចេញមុនម៉ោង។ **ជាការចាំបាច់ណាស់ ដែលលោកអ្នកត្រូវផ្តល់ព័ត៌មានត្រឹមត្រូវឲ្យការិយាល័យសាលា រួមទាំង អាសយដ្ឋានត្រឹមត្រូវ លេខទូរស័ព្ទ ផ្ទះ កន្លែងធ្វើការ និង/ឬ ទូរស័ព្ទដៃ និងឈ្មោះអ្នកដែលគេអាចទាក់ទងបាននៅពេលមានអាសន្ន។**

**កិច្ចការដែលគ្រូឲ្យយកទៅធ្វើនៅផ្ទះ និងសៀវភៅ/HOMEWORK AND BOOKS**

ច្បាប់សម្រាប់កិច្ចការដែលគ្រូឲ្យយកទៅធ្វើនៅផ្ទះរបស់ក្រសួងបានចែងថា ក្មេងនឹងមានកិច្ចការដែលគ្រូឲ្យយកទៅធ្វើនៅផ្ទះ យ៉ាងហោចណាស់ បួនថ្ងៃក្នុងមួយអាទិត្យ។ គ្រូម្នាក់ៗនឹងវាយតម្លៃកិច្ចការដែលបានដាក់ឲ្យសិស្សធ្វើ តាមរបៀបខុសៗគ្នា។ យើងខ្ញុំសង្ឃឹមថាមាតាបិតានឹងសាកសួរគ្រូរបស់កូន។ សុំឲ្យក្មេងទាំងអស់អានយ៉ាងតិច

ណាស់ម្ភៃនាទីក្នុងមួយយប់ៗ។ មាតាបិតាត្រូវអានឲ្យក្មេងស្តាប់ ជាពិសេសនៅពេលពួកគេរៀនថ្នាក់មត្តេយ្យ និងថ្នាក់ទីមួយ។

ក្មេងគ្រប់រូបត្រូវយក សៀវភៅ និងសម្ភារៈសិក្សា ទៅ និងមកពី សាលា ដើម្បីឲ្យពួកគេអាចធ្វើកិច្ចការដែលគ្រូដាក់ឲ្យធ្វើផ្ទះ ឲ្យបានរួចរាល់។ សំពៀតដាក់សៀវភៅមានសុវត្ថិភាពបំផុត ហើយងាយស្រួលបំផុតក្នុងការដាក់សម្ភារៈទាំងនេះ។ សិស្សទាំងអស់ត្រូវមានសៀវភៅសរសេរ ឬសៀវភៅសម្រាប់កិច្ចការសាលា ក្រៅពីសៀវភៅមេរៀនដែលគេធ្វើទៅផ្ទះ។

សៀវភៅមានតម្លៃថ្លៃណាស់។ សូមជំរុញឲ្យកូនរបស់លោកអ្នកថែរក្សាសៀវភៅរបស់ពួកគេ។ នៅពេលណាបាត់សៀវភៅ ឬមានគេលួច គេតម្រូវឲ្យលោកអ្នកបង់ថ្លៃសៀវភៅថ្មី។ គេនឹងផ្តល់ បញ្ជីឈ្មោះសៀវភៅរបស់កូនលោកអ្នក និងតម្លៃសៀវភៅ ដើម្បីទុកជាព័ត៌មានសម្រាប់លោកអ្នក។

### ការមកយឺតមិនទាន់ម៉ោង

ការមកសាលាមិនទាន់ម៉ោងរំខានដល់ សាលា និងថ្នាក់រៀន ហើយជាទម្លាប់មិនល្អ។ កណ្តឹងរបស់យើងរោទិ៍នៅម៉ោង៨:៣០ ព្រឹក។ ក្មេងប្រុស ស្រី ទាំងអស់ ត្រូវតម្រៀបជួរនៅពេលសាលាចាប់ផ្តើមជាផ្លូវការ។ ការចំណាយពេលពីរបីនាទីនៅក្នុងថ្នាក់ត្រៀមខ្លួនចូលរៀន អាចជួយ គ្រូ និងថ្នាក់ ឲ្យចាប់ផ្តើមបានដំណើរការបានល្អ។ ការរៀបចំ សៀវភៅ និងសម្ភារៈ ដែលត្រូវការ គ្រូតពិនិត្យវត្តមានអវត្តមាន ធ្វើការប្រកាស ទុកវត្ថុ ឬសម្លៀកបំពាក់ ។ល។ ទាំងអស់នេះគឺ ជារបស់សំខាន់ៗដែលត្រូវទុកដាក់មុនពេលចាប់ផ្តើមកម្មវិធីបង្ហាត់បង្រៀន។ ត្រូវផ្តល់ឱកាសដល់កូនលោកអ្នកឲ្យចាប់ផ្តើមថ្ងៃរៀនឲ្យបានល្អ។

### អង្គប្រជុំជាមួយមាតាបិតា

សុំឲ្យមាតាបិតាធ្វើការណាត់ជួបប្រជុំជាមួយ នាយកសាលា អ្នកផ្តល់ឱវាទ គិលានុដ្ឋាក ឬ គ្រូ របស់កូន នៅពេលណាលោកអ្នកមានសំណួរ ឬការបារម្ភអ្វី។ លោកអ្នកអាចមកពេលណាក៏បាន។ ទោះជាយ៉ាងដូច្នេះក៏ដោយ ច្បាប់សាលាតម្រូវឲ្យលោកអ្នកមកកាន់ការិយាល័យសាលាជាមុនសិន។ ការណាត់ជួបជាមុនគឺជាវិធីដ៏ល្អបំផុត ដោយសារគ្រូប្រហែលជាមិនអាចនិយាយជាមួយលោកអ្នកបានភ្លាមៗគ្រប់ពេលវេលានោះទេ។

### ការអាន/ភាសា

ក្រសួងអប់រំបញ្ជាឲ្យអនុវត្តនូវ គម្រោងបង្កើនសមត្ថភាពនៃអក្សរសាស្ត្រ (Comprehensive Literacy Framework) នៅក្នុងសាលារបស់ក្រសួងទាំងអស់ សម្រាប់រយៈពេល ១២០ នាទី ក្នុងមួយថ្ងៃ។ សមាសភាគនៃគម្រោងបង្កើនសមត្ថភាពនៃអក្សរសាស្ត្រ ផ្តល់គម្រោងការសម្រាប់ ការបង្ហាត់បង្រៀន និងការអនុវត្តនូវចំណេះដឹង និងវិធីសាស្ត្រ សម្រាប់ ការអាន និងការសរសេរ ដែលមានប្រសិទ្ធិភាព។ សមាសភាគនៃគម្រោងបង្កើនសមត្ថភាពនៃអក្សរសាស្ត្រគឺ៖ អានឮៗ អានរួមគ្នា អានដោយមានការណែនាំ អានដោយខ្លួនឯង សរសេរតាមគំរូ សរសេរឆ្លងឆ្លើយគ្នា/សរសេររួមគ្នា សរសេរដោយមានការណែនាំ និងសរសេរដោយខ្លួនឯង។

> ***អានឮៗ*** - គ្រូជ្រើសរើសអត្ថបទ ហើយអានឲ្យសិស្សានុសិស្សស្តាប់ ដើម្បីណែនាំនូវអត្ថបទដ៏អស្ចារ្យ បង្ហាញភាពមិនដាក់រដុប បង្ហាញមនោសញ្ចេតនានៃការអាន ឬ បង្ហាញ និងបង្រៀននូវចំណេះដឹង នឹងវិធីសាស្ត្រ ដែលត្រូវការ។
>
> ***អានរួមគ្នា*** - គ្រូបង្រៀនដោយផ្ទាល់អំពី ការប៉ិនប្រសប់ និងវិធីសាស្ត្រ នៃការអានដែលមានប្រសិទ្ធិភាព។ សិស្សានុសិស្សមានសៀវភៅដែលគ្រូជ្រើសរើស ហើយអាចអានតាមនៅពេលគ្រូអាន។
>
> ***អានដោយមានការជួយណែនាំ*** - គ្រូផ្តល់ការបង្ហាត់បង្រៀនតាមក្រុមតូចៗ សម្រាប់សិស្សានុសិស្សដែលមាន សេចក្តីត្រូវការ និងកម្រិតនៃការអាន ប្រហាក់ប្រហែលគ្នា។
>
> ***អានដោយខ្លួនឯង*** - ក្នុងមួយថ្ងៃៗ សិស្សានុសិស្សចំណាយពេលអានសៀវភៅដែលគេរើសយកមកអានដោយស្ងាត់ស្ងៀម។ នៅពេលពួកគេអាន ពួកគេអនុវត្ត វិធីសាស្ត្រ និងចំណេះដឹង ដែលគេពួកត្រូវការ ដើម្បីឲ្យខ្លួនក្លាយទៅជាអ្នកអានដែលមានប្រសិទ្ធិភាព។
>
> ***សរសេរតាមគំរូ*** - គ្រូបង្ហាញរបៀបដែលគាត់គិត និងរៀបរៀងសរសេរ នៅពេលសិស្សានុសិស្ស មើល និងស្តាប់។
>
> ***សរសេរឆ្លងឆ្លើយគ្នា/ការសរសេររួមគ្នា*** - គ្រូធ្វើការរួមគ្នាជាមួយសិស្សតាម ក្រុមតូចៗ ឬក្រុមទាំងមូល ដើម្បីរៀបរៀងការសរសេរដំណឹង ឬអត្ថបទ។ គ្រូបង្រៀនដោយផ្ទាល់អំពីចំណេះដឹង និងវិធីសាស្ត្រ នៃការសរសេរដែលមានប្រសិទ្ធិភាព ដោយបង្ហាញ និង/ឬ សុំឲ្យសិស្សានុសិស្សចូលរួមក្នុងការសរសេរ។
>
> ***សរសេរដោយការណែនាំ*** - គ្រូផ្តល់ការបង្ហាត់បង្រៀនតាមក្រុមតូចៗ សម្រាប់សិស្សានុសិស្សដែលមានសេចក្តីត្រូវការប្រហាក់ប្រហែលគ្នា។
>
> ***សរសេរដោយខ្លួនឯង*** - សិស្សានុសិស្សចំណាយពេលសម្រាប់សរសេរ ជារៀងរាល់ថ្ងៃ។ នៅពេលសិស្សសរសេរ ពួកគេអនុវត្ត និងកែលម្អវិធីសាស្ត្រ និងចំណេះដឹង ដែលពួកគេត្រូវការ ដើម្បីធ្វើឲ្យការសរសេរមានភាពសុក្រឹត។

### របាយការណ៍ពិន្ទុ

របាយការណ៍ពិន្ទុរបស់សិស្សនឹងចែកជូនបួនដងក្នុងមួយឆ្នាំ ហើយការជួបប្រជុំអំពីរបាយការណ៍ពិន្ទុ នឹងធ្វើឡើងពីរដងក្នុងមួយឆ្នាំ ដើម្បីផ្តល់ឱកាសជូនលោកអ្នកជួបជាមួយគ្រូរបស់កូនលោកអ្នក ដើម្បីពិភាក្សាពីការរីកចម្រើនរបស់ពួកគេ។ អង្គប្រជុំនឹងប្រព្រឹត្តទៅនៅថ្ងៃខែដូចតទៅ៖ ថ្ងៃទី៤ ទី៥ ខែធ្នូ និង ទី១២ ទី១៣ ខែកុម្ភៈ។ របាយការណ៍ពិន្ទុចុងក្រោយបង្អស់នឹងផ្ញើទៅផ្ទះនៅថ្ងៃរៀនចុងក្រោយបង្អស់ក្នុងខែមិថុនា។ របាយការណ៍នៅចន្លោះពេលនេះនឹងចែកជូនដោយគ្រូ ជាបន្តបន្ទប់នៅក្នុងឆ្នាំសិក្សា។

**សុវត្ថិភាព**

ដើម្បីផ្តល់សុវត្ថិភាពខ្ពស់បំផុតដល់កូនលោកអ្នក យើងខ្ញុំសុំឲ្យលោកអ្នកជួយ តាមរយៈការអនុវត្តន៍តាមសេចក្តីណែនាំជាមូលដ្ឋានដូចតទៅនេះ។ បើសិនជាលោកអ្នកនាំកូនដើរទៅ ឬមកពី សាលា គឺជាការសំខាន់ណាស់ ដែលកូនលោកអ្នកត្រូវមកដល់សាលាឲ្យទាន់ម៉ោងជារៀងរាល់ថ្ងៃ ហើយត្រូវមកទទួលកូនឲ្យទាន់ម៉ោង ៣:០៩ រសៀល។ ដោយសារគ្មានកន្លែងគ្រប់គ្រាន់នៅសាលា យើ ហើយមូលហេតុដែលតម្រូវឲ្យយើងខ្ញុំរក្សា ជណ្តើរ និងរបៀងសាលាបើកចំហ សម្រាប់ការធ្វើដំណើរ យើងខ្ញុំស្នើសុំឲ្យលោកអ្នកទុកកូននៅពេលកណ្តឹងរោទិ៍សម្រាប់ពេលចូលរៀន ហើយសុំឲ្យលោកអ្នករង់ចាំកូននៅខាងក្រៅ នៅពេលកូនចេញពីរៀន។ នឹងមានការលើកលែងនៅពេលណាមានអាកាសធាតុមិនល្អ។ បើសិនជាលោកអ្នកបញ្ជូនកូនឲ្យមករៀនដោយខ្លួនឯង សូមកុំបញ្ជូនពួកគេមកមុនម៉ោង៨:៣០ ព្រឹក ពេក ដោយសារយើងខ្ញុំគ្មានកន្លែងគ្រប់គ្រាន់សម្រាប់ការមើលខុសត្រូវនៅក្នុងអាគារ។

សូមកត់សម្គាល់ថា ជាផ្នែកមួយនៃកម្មវិធីសុវត្ថិភាពរបស់សាលា យើងនឹងមានការហ្វឹកហាត់របៀបត្រៀមខ្លួននៅពេលមានអគ្គីភ័យ និងការលាក់ខ្លួននៅពេលមានអាសន្ន (Fire Drills and Shelter In Place Drills) តាមការតម្រូវឲ្យធ្វើ។ នៅពេលហ្វឹកហាត់ពីរបៀបត្រៀមខ្លួន ពេលមានអគ្គីភ័យ (Fire Drills) យើងខ្ញុំសុំឲ្យអ្នកទាំងអស់ចេញពីអាគារ។ នៅពេលហ្វឹកហាត់ពីរបៀបលាក់ខ្លួនពេលមានអាសន្ន (Shelter In Place Drills) យើងខ្ញុំសុំឲ្យអ្នកដែលនៅក្នុងអាគារ រក្សានៅក្នុងអាគារដដែល ហើយអ្នកដែលនៅក្រៅអាគារ រក្សានៅក្រៅអាគារដដែល រហូតដល់ពេលការហ្វឹកហាត់នេះចប់សព្វគ្រប់។

យើងខ្ញុំមានម៉ាស៊ីនថតសម្រាប់ការពារសន្តិសុខចំនួនដប់បួន ដែលឈ្លបមើលសកម្មភាពខាងក្នុង និងខាងក្រៅ សាលា។ ជាបន្ថែមទៀត មានម៉ាស៊ីនថតមួយនៅខាងក្រៅទ្វារខាង ផ្លូវលេខ៨ និង ផ្លូវ Wolf។ សូមជ្រាបថា គេនឹងចាក់សោទ្វារទាំងអស់មិនអាចឲ្យចូលពីក្រៅមកបាន ក្រោយម៉ោង ៨:៣០ ព្រឹក។ ហេតុដូច្នេះ អ្នកដែលមកកាន់សាលាទាំងអស់ត្រូវចុចកណ្តឹងដែលនៅលើម៉ាស៊ីនថត ដើម្បីឲ្យគេចុចបើកទ្វារឲ្យ។

**ការធ្វើដំណើរកំសាន្តរបស់សាលា**

ការធ្វើដំណើរកំសាន្តរបស់សាលាទាំងអស់ត្រូវមានការយល់ព្រមពីនាយកសាលា។ មាតាបិតា/អាណាព្យាបាល ត្រូវចុះហត្ថលេខាលើលិខិតអនុញ្ញាតឲ្យសិស្សធ្វើដំណើរ ហើយប្រគល់ទៅឲ្យសាលាវិញ មុនពេលការធ្វើដំណើរកំសាន្តរបស់ថ្នាក់។ **គេនឹងមិនអនុញ្ញាតឲ្យសិស្សណាម្នាក់ចូលរួមក្នុងការធ្វើដំណើរកំសាន្តរបស់ថ្នាក់ដោយគ្មានការចុះហត្ថលេខាលើលិខិតអនុញ្ញាតឲ្យសិស្សធ្វើដំណើរនោះបានទេ។ គេមិនទទួលស្គាល់ ការទូរស័ព្ទទៅគ្រូដើម្បីផ្តល់ការអនុញ្ញាតឲ្យសិស្សធ្វើដំណើរនោះ ទេ។** នៅពេលខ្លះ មាតាបិតាត្រូវបង់ថ្លៃរថយន្តសម្រាប់ការធ្វើដំណើរកំសាន្តរបស់សាលា។ បុគ្គលិករបស់ក្រសួងអប់រំ មិនអាចប្រើរថយន្តផ្ទាល់ខ្លួន ដើម្បីដឹកសិស្សក្នុងការធ្វើដំណើរទៅកន្លែងណាមួយបានទេ។ ដើម្បីជួយដល់ការមើលខុសត្រូវក្មេង គេតម្រូវឲ្យមានមនុស្សពេញវ័យម្នាក់ មើលសិស្សដប់នាក់ សម្រាប់ករធ្វើដំណើររបស់សាលា។ សុំឲ្យ មាតាបិតា និងមនុស្សពេញវ័យ ស្ម័គ្រចិត្តជួយបុគ្គលិកសាលា ចំពោះការធ្វើដំណើររបស់សាលា នៅពេលដែលគេត្រូវការ។ គេអាចបដិសេធមិនឲ្យសិស្សដែលបានទទួលទណ្ឌកម្មដោយសារការរំខាន និងអាកប្បកិរិយាដែលមិនសមរម្យ ចូលរួមដំណើរកំសាន្តរបស់សាលា។ គេតម្រូវឲ្យសិស្សស្លៀកពាក់**ឯកសណ្ឋានសាលា**គ្រប់ពេលធ្វើដំណើរទាំងអស់ លើកលែងតែនៅពេលណាដែលបានបញ្ជាក់នៅលើលិខិតអនុញ្ញាតថាមិនត្រូវការឯកសណ្ឋាន។

**ការប្រើគ្រឿងបច្ចេកទេស និងអ៊ិនធ័រណិត**

យើងប្រើកុំព្យូទ័រ Apple នៅក្នុងថ្នាក់រៀនទាំងអស់។ យើងមានបណ្ណាល័យស្វ័យប្រវត្តគ្រប់គ្រាន់។ គ្រប់ថ្នាក់រៀនទាំងអស់មានខ្សែកាបជាស្រេច ហើយសាលារបស់យើងមានខ្សែសម្រាប់អ៊ិនធ័រណិត និងបណ្តាញកុំព្យូទ័រសម្រាប់ផ្លាស់ប្តូរឬមើលព័ត៌មាន។ វិបសៃរបស់យើងមានព័ត៌មានល្អៗ ដែលជួយពង្រីកឱកាសសិក្សាដល់លោកអ្នក និងកូន។ អាស័យដ្ឋាននៃគេហទំព័ររបស់យើងគឺ៖ http://www.philasd.org/schools/key។

**ច្បាប់ឯកសណ្ឋាន -- ច្បាប់សម្លៀកបំពាក់**

ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យាបានអនុម័តឲ្យមានច្បាប់ឯកសណ្ឋានសម្រាប់សិស្សានុសិស្សទាំងអស់។ ច្បាប់នេះតម្រូវថា ឯកសណ្ឋានបានឲ្យនិយមន័យថាជាសម្លៀកបំពាក់ដែលមានម៉ូដ និងពណ៌ ដូចគ្នា ដែលសាលានីមួយៗត្រូវទទួលខុសត្រូវក្នុងការសម្រេចអំពីកម្មវិធីឯកសណ្ឋាន។ យោងទៅលើលទ្ធផលនៃការស្ទង់មតិមាតាបិតារបស់យើង និងដើម្បីធ្វើតាមការតម្រូវនេះ សាលា Key នឹងអនុវត្តច្បាប់ឯកសណ្ឋានដូចតទៅនេះ។ ពណ៌ឯកសណ្ឋានរបស់យើង គឺពណ៌ទឹកប៊ិចចាស់ និងពណ៌ស។ ក្មេងប្រុសត្រូវស្លៀកខោពណ៌ទឹកប៊ិចចាស់ ហើយពាក់អាវពណ៌ស។ គេមិនអនុញ្ញាតឲ្យស្លៀក ខោខូវប៊យពណ៌ខៀវ និងពាក់អាវក្នុង ធ្វើជាអាវធម្មតាបានទេ។ ក្មេងស្រីត្រូវស្លៀកខោបារាំងជើងវែង សំពត់ ឬសំពត់មានខ្សែពាក់លើស្មា ពណ៌ទឹកប៊ិចចាស់ ជាមួយអាវពណ៌ស។ គេមិនអនុញ្ញាតឲ្យស្លៀក ខោ ឬសំពត់ខ្លី ខោខ្លីរលុងៗសម្រាប់ស្ត្រី និងអាវម្យ៉ាងដែលគ្របតែដោះហើយមានខ្សែចងទៅនឹងក ទេ។ អាចពាក់ ស្បែកជើងដែលគ្របម្រាមជើង និងស្បែកជើងប៉ាតា។ មិនអនុញ្ញាតឲ្យពាក់ ស្បែកជើងសង្រែក និងស្បែកជើងផ្ទាត់ ទេ។ ហាមដាច់ខាតមិនឲ្យស្លៀកពាក់សម្លៀកបំពាក់ដែលមាន ពាក្យ ឬរូប អាសគ្រាម។

**វិធីសម្រាប់អ្នកមកកាន់សាលាចុះហត្ថលេខា**

សុំឲ្យអ្នកដែលមកកាន់សាលាទាំងអស់ ទៅកាន់ការិយាល័យសាលា។ គេនឹងសុំឲ្យអ្នកមកកាន់សាលាចុះហត្ថលេខានៅក្នុងសៀវភៅសម្រាប់អ្នកមកកាន់សាលា "Visitor's Book" ហើយយក ផ្លាកសម្គាល់ "Visitor Badge" មុននឹងធ្វើដំណើរទៅកាន់ទីកន្លែងផ្សេងៗទៀតនៅក្នុងអាគារ។ អ្នកចាំទទួលមាតាបិតានៅតុស្វាគមន៍របស់យើងនឹងបង្ហាញផ្លូវទៅកាន់ការិយាល័យសាលាដល់អ្នកដែលមកកាន់សាលាទាំងអស់។